# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតកំពង់ផែទេសចរណ៍អន្តរជាតិកំពត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៤/០០២ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៦ ស្តីពីសន្តិសុខនាវានិងសន្តិសុខបបនីយកណ្តាលដែ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតកំពង់ផែទេសចរណ៍អន្តរជាតិកំពត ដែលសរសេរជាអក្សរកាត់ថា **ក.ទ.ក**. និងមានឈ្មោះជាភាសាអង់គ្លេសថា Kampot International Tourism Port ដែលមានទីតាំងស្ថិតនៅភូមិជុំគ្រៀល ឃុំជុំគ្រៀល ស្រុកទឹកឈូ ខេត្តកំពត ដើម្បីបម្រើសេវាឱ្យនាវាដឹកអ្នកដំណើរដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ ជាមួយប្រទេសជិតខាង និងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា២ .-**

កំពង់ផែទេសចរណ៍អន្តរជាតិកំពតជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងសាធារណការនិងដឹកជញ្ជូនជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា៣ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន ជាអង្គគ្រប់គ្រងកំពង់ផែនៃកំពង់ផែទេសចរណ៍អន្តរជាតិកំពត។

**មាត្រា៤ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូនអាចប្រគល់កំពង់ផែទេសចរណ៍អន្តរជាតិកំពតទៅឱ្យក្រុមហ៊ុនឯកជនធ្វើជាប្រតិបត្តិករកំពង់ផែដើម្បីធ្វើប្រតិបត្តិការនិងថែទាំតាមរយៈការរៀបចំឱ្យមានកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនឯកជននោះ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្រសួងសាធារណការនិងដឹកជញ្ជូនត្រូវរៀបចំយន្តការសម្របសម្រួល តាមដាន និងត្រួតពិនិត្យការអនុវត្តសិទ្ធិនិងកាតព្វកិច្ចដែលបានបញ្ញត្តនៅក្នុងកិច្ចព្រមព្រៀង ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ។

**មាត្រា៥ .-**

ប្រតិបត្តិករកំពង់ផែនៃកំពង់ផែទេសចរណ៍អន្តរជាតិកំពត ត្រូវអនុវត្តសិទ្ធិនិងកាតព្វកិច្ចដែលបានបញ្ញត្តនៅក្នុងកិច្ចព្រមព្រៀង ដូចមានចែងនៅក្នុងកថាខណ្ឌទី១ មាត្រា៤នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## ការកំណត់ដែនកំពង់ផែ

**មាត្រា៦ .-**

កំពង់ផែទេសចរណ៍អន្តរជាតិកំពតមានដែនទឹកនិងដីគោក។

ដែនទឹកមានទំហំ២៧៩,៩៨៥៧(ពីររយចិតសិបប្រាំបួនក្បៀសប្រាំបួនពាន់ប្រាំបីរយហាសិបប្រាំពីរ) ហិកតា និងដីគោកមានទំហំ៣,៧៧៤២(បីក្បៀសប្រាំពីរពាន់ប្រាំពីររយសែសិបពីរ)ហិកតា មានព្រំដែននិងនិយាមកានៅក្នុងគម្រោងប្លង់រួមនៃកំពង់ផែទេសចរណ៍អន្តរជាតិកំពត ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៧ .-**

ដែនទឹកនៃកំពង់ផែទេសចរណ៍អន្តរជាតិកំពតដូចមានចែងក្នុងកថាខណ្ឌទី២ មាត្រា៦នៃអនុក្រឹត្យនេះ ត្រូវទុកជាកម្មវត្ថុសម្រាប់ការគ្រប់គ្រងនិងប្រើប្រាស់ដោយអង្គគ្រប់គ្រងកំពង់ផែទេសចរណ៍អន្តរជាតិកំពត ដែលរួមមាន ប្រឡាយនាវាចរណ៍ សញ្ញាជំនួយនាវាចរណ៍ អាងបត់នាវា និងឋបនីយកណ្ឌផ្សេងទៀត ដើម្បីធានាដល់កិច្ចការពារសុវត្ថិភាព សន្តិសុខ និងបរិស្ថាន នៅក្នុងដែនទឹកនៃកំពង់ផែនេះ។

## ជំពូកទី៤
## ឋបនីយកណ្ឌផែ

**មាត្រា៨ .-**

ឋបនីយកណ្ឌសំខាន់ៗក្នុងដែនទឹកនៃកំពង់ផែទេសចរណ៍អន្តរជាតិកំពត មានដូចខាងក្រោម៖

- ប្រឡាយនាវាចរណ៍ មានទទឹងពី១៦០(មួយរយហុកសិប)ម៉ែត្រ ដល់៣៤០(បីរយសែសិប)ម៉ែត្រ និងបណ្តោយ១៥(ដប់ប្រាំ)គីឡូម៉ែត្រ ដោយគិតចាប់ពីនិយាមកាលេខសេសពីលេខ១ដល់លេខ៦៧ និងនិយាមកាលេខគូពីលេខ២ដល់លេខ៧២
- អាងបត់នាវា ដែលជាផ្នែកមួយនៃប្រឡាយនាវាចរណ៍ មានអង្កត់ផ្ចិតប្រវែង២៥០(ពីររយហាសិប)ម៉ែត្រ ដែលមានចំណុចផ្ចិតស្ថិតនៅលើចំណុចនិយាមកា X 414198, Y 1168321
- សញ្ញាជំនួយនាវាចរណ៍ ប្រព័ន្ធ និងឋបនីយកណ្ឌផ្សេងទៀត ដែលចាំបាច់ធានាដល់សុវត្ថិភាព សន្តិសុខ និងបរិស្ថាន សម្រាប់នាវាដែលធ្វើនាវាចរណ៍ឆ្លងកាត់ប្រឡាយនាវាចរណ៍នៃកំពង់ផែទេសចរណ៍អន្តរជាតិកំពត។

**មាត្រា៩ .-**

ឋបនីយកណ្ឌសំខាន់ៗនៅលើដីគោកនៃកំពង់ផែទេសចរណ៍អន្តរជាតិកំពត ចែកចេញជាពីរផ្នែក ដូចខាងក្រោម៖

ផ្នែកទី១ ជាទីបរិវេណស្នាក់ការមេ រួមមានអគាររដ្ឋបាល អគារបច្ចេកទេស បន្ទប់ទឹកសាធារណៈ ឋបនីយកណ្ឌទទួលសំរាម អាងស្តុកទឹកក្រោមដី ចំណតរថយន្ត សួនច្បារ ស្រះទឹក ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹកស្អាត ស្ថានីយ៍និងប្រព័ន្ធចម្រោះទឹកកខ្វក់ ប្រព័ន្ធពន្លត់អគ្គីភ័យ និងរបងព័ទ្ធជុំវិញដែលមានច្រកចូល ច្រកចេញ ច្រកចូលចេញ និងប៉ុស្តិ៍យាម ដើម្បីធានាដល់ប្រតិបត្តិការកំពង់ផែ ប្រកបដោយសន្តិសុខ សុវត្ថិភាព និងបរិស្ថាន និងមានទំហំ៣,៣៨២៦(បីក្បៀសបីពាន់ប្រាំបីរយម្ភៃប្រាំមួយ)ហិកតា ស្ថិតនៅលើនិយាមកាពីលេខ១ដល់លេខ៦។

ផ្នែកទី២ ជាចំណតនាវា ស្ថិតនៅលើមាត់ព្រែក មានទំហំ០,៣៥១៦(សូន្យក្បៀសបីពាន់ប្រាំបួនរយដប់ប្រាំមួយ)ហិកតា និងមានប្រវែង១០៣(មួយរយបី)ម៉ែត្រ ស្ថិតនៅលើនិយាមកាពីលេខ១ដល់លេខ៦។

**មាត្រា១០ .-**

អគាររដ្ឋបាលនៃកំពង់ផែទេសចរណ៍អន្តរជាតិកំពត ជាច្រកចូលចេញនៃអ្នកដំណើរ មានកន្លែងអ្នកដំណើររង់ចាំ ការិយាល័យធ្វើការរបស់ប្រតិបត្តិករកំពង់ផែនិងមន្ត្រីមានសមត្ថកិច្ច។

## ជំពូកទី៥
## មន្ត្រីមានសមត្ថកិច្ចប្រចាំការនៅកំពង់ផែ

**មាត្រា១១ .-**

កំពង់ផែទេសចរណ៍អន្តរជាតិកំពត ត្រូវមានមន្ត្រីមានសមត្ថកិច្ចប្រចាំការ ដែលរួមមាន មន្ត្រីចត្តាឡីស័កនៃក្រសួងសុខាភិបាល មន្ត្រីនគរបាលអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ មន្ត្រីគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមេបញ្ជាការផែនៃក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីអនុវត្តច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក ច្បាប់ផ្សេងទៀតនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១១កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែមេសា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

**ប៉េង ពោធិ៍នា**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ២០២៥

ស្តីពីការបង្កើតកំពង់ផែទេសចរណ៍អន្តរជាតិកំពត

# គម្រោងប្លង់រួមនៃកំពង់ផែទេសចរណ៍អន្តរជាតិកំពត

